គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

## គណៈកម្មាធិការប្រព្រឹត្តិកម្ម ស្វាគមន៍ចំពោះភាពជឿនលឿននៅក្នុងដំណើរការនៃ យន្តការពិនិត្យជាទៀងទាត់តាមកាលកំណត់ជាលើកដំបូង (UPR) របស់ប្រទេសកម្ពុជា

នៅក្នុងឱកាសលើកទី១៣នៃ កិច្ចប្រជុំពេញអង្គរបស់គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅឯទីក្រុងហ្សឺណែវ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធដែលមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន២៣ជាសមាជិកបំរើកប្រារលើវិស័យសិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា សូមសំដែងនូវការស្វាគមន៍ចំពោះសេចក្តីសំរេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានយល់ព្រមទទួលយកនូវអនុសាសន៍ទាំង៩១ ដែលបានផ្តល់ដោយសមាជិកនៃគណៈកម្មការសិទ្ធិមនុស្ស នៅក្នុងក្របខណ្ឌនៃដំណើរការកិច្ចប្រជុំយន្តការពិនិត្យជាទៀងទាត់តាមកាលកំណត់ (Universal Period Review-UPR)។ ការទទួលយកនូវអនុសាសន៍ទាំងនេះ គឺជាសញ្ញាវិជ្ជមានដ៏សំខាន់មួយ ហើយយើងក៏សូមជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាត់វិធានការដ៏គួរឱ្យជឿជាក់ថែមទៀត ក្នុងការអនុវត្តន៍នូវអនុសាសន៍ទាំងអស់នោះនៅក្នុងរយៈពេល៤ឆ្នាំខាងមុខទៀត នៅពេលដែលប្រទេសកម្ពុជានឹងត្រូវដាក់ឱ្យស្ថិតនៅក្នុងការពិនិត្យសារជាថ្មីទៀត។

យន្តការពិនិត្យជាទៀងទាត់តាមកាលកំណត់ (UPR) នេះ គឺយន្តការត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សថ្មីមួយរបស់គណៈកម្មការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ ដែលត្រូវដាក់ប្រទេសទាំងឡាយដែលជាសមាជិកនៃអង្គការពិភពលោកនេះ ឱ្យស្ថិតនៅក្រោមការពិនិត្យរបស់បណ្តារដ្ឋជាសមាជិកដទៃទៀត នៅរៀងរាល់៤ឆ្នាំម្តង។ ការពិត គណៈកម្មាធិការប្រព្រឹត្តិកម្ម រួមនឹងអង្គការសង្គមស៊ីវិលកម្ពុជាដទៃទៀត ក៏បានគាំទ្រនូវដំណើរការនេះផងដែរដោយបានដាក់បញ្ជូននូវរបាយការណ៍សង្ខេបរបស់ខ្លួនទៅកាន់គណៈកម្មការសិទ្ធិមនុស្ស កាលពីឆ្នាំ២០០៩។ នៅក្នុងកិច្ចប្រជុំនៃក្រុមការងាររបស់គណៈកម្មការសិទ្ធិមនុស្ស កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ សមាជិកដទៃនៃគណៈកម្មការសិទ្ធិមនុស្សបានចេញអនុសាសន៍ចំនួន៩១ ប្រកបដោយអត្ថន័យ និងច្បាស់លាស់ ជូនដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវកំណត់ត្រាអំពីបញ្ហាសិទ្ធិមនុស្សរបស់ប្រទេសខ្លួន។ ដោយសារតែ ពេលឥឡូវនេះ រាជរដ្ឋាភិបាលបានទទួលយករួចហើយ នោះ អនុសាសន៍ទាំងនេះ គឺជាសូចនាករដ៏សំខាន់

សំរាប់ធ្វើការតាមដាននូវភាពជឿនលឿននៅក្នុងការអនុវត្តន៍ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើបញ្ហាទាំងនេះ ។

ជាជំហានបន្ទាប់ទៀត គឺថា រាជរដ្ឋាភិបាលកម្ពុជា ក៏គួរតែពិចារណាបង្កើតនូវផែនការងារ ឬផែនការសកម្មភាព ដើម្បីចាប់ផ្ដើមអនុវត្តន៍នូវអនុសាសន៍ទាំងនោះជាបន្តបន្ទាប់ផងដែរ ។ អាទិភាពជាបន្ទាន់នោះ គឺទាក់ទិននឹងអនុសាសន៍ទៅលើបញ្ហារំលោភសិទ្ធិដីធ្លី, កំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ និងសេរីភាពក្នុងការបញ្ចេញមតិ ។ គណៈកម្មាធិការប្រព្រឹត្តិកម្ម និងអង្គការសង្គមស៊ីវិលដទៃទៀត ត្រៀមខ្លួនជាស្រេច ដើម្បីជួយជ្រោមជ្រែងការអនុវត្តន៍នូវអនុសាសន៍ទាំងនោះ តាមរយៈការចូលរួមយ៉ាងសកម្ម និងបន្តឃ្លាំមើលតាមដានទៅលើដំណើរការនេះ ។ ការទទួលយកនូវអនុសាសន៍ទាំងនេះ វាគ្រាន់តែជាជំហានទី១ ទេ ហើយយើងសង្ឃឹមថា ចាប់ពីនេះទៅ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តការប្ដេជ្ញាចិត្ត និងការខិតខំធ្វើការងាររបស់ខ្លួន ដើម្បីឈានទៅធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាយើងជាបន្តបន្ទាប់ អនុឡោមទៅតាមរដ្ឋធម្មនុញ្ញរបស់យើង ដែលបានចែងទទួលស្គាល់ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ។

*ភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០*

***<u>សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:</u>***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី **សយ សារាវឡនី** | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |